**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ១៥០៩ ព.ណ.កពា.

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែ អាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៨

## សេចក្តីជូនដំណឹង

ក្នុងនាមគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំ និងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងទៅដល់ពាណិជ្ជករ និងអាជីវករទាំងអស់ ឲ្យបានជ្រាបថា៖ កម្ពុជានឹងត្រូវធ្វើជាប្រទេសកិត្តិយស ក្នុងការចូលរួមពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន លើកទី១៥ ឆ្នាំ២០១៨ "The 15th China-ASEAN Expo 2018" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១២-១៥ ខែកញ្ញា ឆ្នាំ២០១៨ នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិ ទីក្រុងណាននីង ខេត្តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន។ ក្នុងនាមជាប្រទេសកិត្តិយសនៅក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ កម្ពុជា នឹងរៀបចំនូវកម្មវិធី ដូចខាងក្រោម៖

១- រៀបចំ ពន្លាជាតិកម្ពុជា និងតាំងបង្ហាញផលិតផលខ្មែរ
២-រៀបចំ ដំណើរទេស្សនកិច្ចពាណិជ្ជកម្ម នៅតាមបណ្តាក្រុមហ៊ុន សហគ្រាស និងចូលរួមវេទិកាធុរកិច្ច និងវិនិយោគផ្សេងៗ នៅក្នុងប្រទេសចិន
៣-រៀបចំ វេទិកាស្តីពីពាណិជ្ជកម្ម និងវិនិយោគកម្ពុជា-ចិន លើកទី៣ នៅព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨
៤-រៀបចំ វេទិកាធុរកិច្ចនិងវិនិយោគ ពិធីចុះហត្ថលេខា លើអនុស្សរណៈយោគយល់គ្នា "MOU" និងកម្មវិធីជំនួបពាណិជ្ជកម្ម នៅរសៀលថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញពាណិជ្ជករ និងអាជីវករទាំងអស់ ដែលមានបំណងទៅចូលរួមពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ាន លើកទី១៥ ឆ្នាំ២០១៨ ឬមានគម្រោងស្វែងរកដៃគូវិនិយោគ ឬត្រូវចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយដៃគូរបស់ខ្លួន មេត្តាប្រញាប់រួសរាន់ មកបំពេញបែបបទ និងផ្ញើគម្រោងរបស់ខ្លួនមក នាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម **ឲ្យបានមុនថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ជាកំហិត។**

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង នាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០១៧ ៧៥៩ ៥៦៧ ឬ ០៨៦ ៣៣៣ ៩៣៣ ឬ ០១២ ៦០០ ៧៧៨ ឬ ០៩៥ ៩២៩ ១៩២ ឬ ០១៧ ៥៥៩ ២៧៧

អាសយដ្ឋានអ៊ីម៉ែល៖ vannameass@yahoo.com ឬ sorn_pitou@yahoo.com veasna_mao@yahoo.com ឬ saraysin@yahoo.com ឬ vitholt@yahoo.com

**សូមអរគុណ!**

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce
Nº 1509.MOC.D./EA

# KINGDOM OF CAMBODIA

**Nation - Religion - King**

Phnom Penh, 26 April, 2018

## ANNOUNCEMENT

On behalf of the Cambodian Inter-Ministerial Committee for Participation in the World Expo and the International Trade Exhibitions, the Ministry of Commerce has the honor to inform all traders and businessmen that Cambodia will be the Country of Honor in the "15th China-ASEAN Expo 2018", which will be held from 12-15 September, 2018 at Nanning International Convention and Exhibition Center, Nanning City, Guangxi Zhuang Autonomous Region of P.R of China. As the Country of Honor in this expo event, Cambodia will hold the programs as follows:

1- Display Cambodia National Pavilion and showcase the Made-in-Cambodia products,
2- Arrange trade visit to Chinese enterprises and attend other business and investment forum in China,
3- Organize the 3rd Cambodia-China Trade and Investment Forum on 13th September, 2018
4- Organize the Forum on "Business and Investment Opportunities in Cambodia", MOU Signing Ceremony, and Trade Matching Program on 13th September, 2018.

In this regard, all relevant traders and businessmen who intend to participate in the "15th China-ASEAN Expo 2018" or wish to find their investment partners or sign MOU with their counterparts are requested to apply and submit their projects to Department of Exhibition Affairs, General Directorate of Trade Promotion of the Ministry of Commerce **no later than 05th August 2018**.

For further information, please contact the Department of Exhibition Affairs, General Directorate of Trade Promotion, Ministry of Commerce at Lot No. 19-61, Russian Federation Blvd, Phum Toek Thla, Sangkat Toek Thla, Khan Sen Sok, Phnom Penh, Cambodia.

Tel: 017 759 567 / 086 333 933 / 012 600 778
095 929 192 / 017 555 799

E-mail: vannameass@yahoo.com / sorn_pitou@yahoo.com / veasna_mao@yahoo.com / saraysin@yahoo.com / vitholt@yahoo.com

Thank you !